១៧-លោក គង់ សាមឿន អភិបាលខ័ណ្ឌដូនពេញ សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

-ទទួលខុសត្រូវក្នុងការរៀបចំ និងទុកដាក់សំណើឯកសារពាណិជ្ជកម្មនេះអោយបានត្រឹមត្រូវ

-ទទួលខុសត្រូវក្នុងការរកសំភារៈ និងឧបករណ៍ដើម្បីដំណើរការ ។

-ទទួលខុសត្រូវក្នុងការសំអាតទីតាំង ។

ប្រការ ៣ : អភិបាលក្រុងព្រះសីហនុ ត្រូវសហប្រតិបត្តិការ និងសំរបសំរួលជាមួយគណៈកម្មការនេះបំពេញភារកិច្ចអោយបានល្អ និងប្រកបដោយប្រសិទ្ធិភាព ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អភិបាលក្រុងព្រះសីហនុ កំពង់ផែក្រុងព្រះសីហនុ មន្ទីរហិរញ្ញវត្ថុក្រុងព្រះសីហនុ មន្ទីរបរិស្ថានក្រុងព្រះសីហនុ មន្ទីរសុខាភិបាលក្រុងព្រះសីហនុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី ស្តីទី

ហត្ថលេខានិងត្រា

ស ខេង

=======

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

## សេចក្តីសំរេច លេខ ៥០ សសរ

**ស្តីពីការបន្ថែមខ្លឹមសារលើការអនុញ្ញាតអោយក្រុមហ៊ុន AZ Distribution Co.LTD**
**ធ្វើជាដៃគូផ្គត់ផ្គង់នូវ រាល់សំភារៈបរិក្ខារ ឧបករណ៍គ្រប់ប្រភេទ**
**ជូនក្រសួងការពារជាតិ ចាប់ពីឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០០៥**

****

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

-យោងតាមសំណើររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៨

**សំរេច**

ប្រការ១ : ត្រូវបានបន្ថែមខ្លឹមសារដូចខាងក្រោមនៅក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៣៧ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន AZ Distribution CO.LTD ធ្វើជាដៃគូផ្គត់ផ្គង់ ម្ហូបអាហារ សំភារៈ បរិក្ខារ ឧបករណ៍ គ្រប់ប្រភេទជូនក្រសួងការពារជាតិ ចាប់ពីឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០០៥ ៖

-សេចក្តីសំរេចនេះមិនអោយជាន់ជាមួយសេចក្តីសំរេចលេខ ៤០ សសរ ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការប្រគល់សិទ្ធិអោយក្រុមហ៊ុនសុគីមិត្ត ផ្គត់ផ្គង់ជូនក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

-ចំពោះគ្រឿងចក្រវិស្វកម្មចំនួន ២៧៩ គ្រឿង សំរាប់ផែនការ ៥ឆ្នាំ ដែលស្នើដោយឯកឧត្តមរដ្ឋមន្ត្រី ទៀ បាញ់ ហើយដែលត្រូវទូទាត់តាមដំណាក់កាលៗរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩ ទៅ ត្រូវរក្សាទុកជូន ក្រុមហ៊ុន AZ Distribution CO.LTD ដដែល ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធក្រុមហ៊ុន AZ Distribution CO.LTD មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

====

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ៥១ សសរ

## ស្តីពីការកែសំរួលកំណត់ទីតាំងលេងល្បែងស៊ីសង កាស៊ីណូ

* * * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី